# I - រាជរដ្ឋាភិបាល

## អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ : ២១ អនក្រ.បក**

**ស្តីពីការកាត់បន្ថយ មន្ត្រី បុគ្គលិក រាជការស៊ីវិល**

នៅដើមឆ្នាំ ១៩៩៧

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទម្រង់រដ្ឋបាល
- ផ្អែកតាមសំណើរបស់គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទម្រង់រដ្ឋបាល

**សំរេច**

**មាត្រា ១ :** ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ នូវមន្ត្រី បុគ្គលិក រាជការ ស៊ីវិល ដែលបានបោះបង់ចោលការងារកន្លងមក នៅតាមក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង នានា ចំនួន ៤.៤២៨ នាក់ ដូចមានឧបសម្ព័ន្ធទី ១ ភ្ជាប់មកជាមួយ ។

**មាត្រា ២ :** ត្រូវបានដាក់អោយចូលនិវត្តន៍ចំពោះមន្ត្រី បុគ្គលិក រាជការ ស៊ីវិល ដែលដល់អាយុចូលនិវត្តន៍នៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង នានាចំនួន ១.៦៥០ នាក់ ដូចមានឧបសម្ព័ន្ធទី ២ ភ្ជាប់មកជាមួយ ។

**មាត្រា ៣ :** ត្រូវបានដាក់អោយបាត់បង់សមត្ថភាពពលកម្ម ចំពោះមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលមានកាយសម្បទាទ្រុឌទ្រោមពុំមានលទ្ធភាពបំពេញការងារជូនរាជរដ្ឋាភិបាល នៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង នានាចំនួន ២៥៣ នាក់ ដូចមាន ឧបសម្ព័ន្ធទី ៣ ភ្ជាប់មកជាមួយ ។

**មាត្រា ៤ :** ត្រូវបានដកចេញពីក្របខ័ណ្ឌរដ្ឋ នូវបុគ្គលិកអណ្តែត និងបុគ្គលិកជាប់កិច្ចសន្យា ដែលមានឈ្មោះក្នុងតារាងបៀវត្ស នៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុងចំនួន ៣៧ នាក់ ដូចមាន ឧបសម្ព័ន្ធទី ៤ ភ្ជាប់មកជាមួយ ។

**មាត្រា ៥ :** ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រី បុគ្គលិក រាជការ នៃរដ្ឋបាលស៊ីវិល បញ្ជូនទៅបំរើការងារផ្នែកការងារនគរបាលជាតិ នៃក្រសួងមហាផ្ទៃ អង្គភាពម្ចាស់ការហិរញ្ញវត្ថុ និង ស្វ័យាភិបាលសេដ្ឋកិច្ចចំនួន ១.២៦២ នាក់ ដូចមានឧបសម្ព័ន្ធទី ៥ ភ្ជាប់មកជាមួយ ។

**មាត្រា ៦ :** ត្រូវបានរក្សាក្របខ័ណ្ឌនៅក្រសួង ស្ថាប័នដើម ចំពោះមន្ត្រី បុគ្គលិក រាជការ ដែលបានទៅបំរើការងារការទូតនៅបរទេស ចំនួន ៣៩ នាក់ ដូចមាន ឧបសម្ព័ន្ធទី ៦ ភ្ជាប់មកជាមួយ ។

**មាត្រា ៧ :** ការលុបឈ្មោះចេញពីក្របខ័ណ្ឌ កការដាក់អោយចូលនិវត្តន៍ ការដាក់អោយបាត់បង់សមត្ថភាពពលកម្ម ការដកចេញពីក្របខ័ណ្ឌរដ្ឋនូវបុគ្គលិកអណ្តែត និង បុគ្គលិកជាប់កិច្ចសន្យា ការផ្ទេរក្របខ័ណ្ឌទៅបំរើការងារនៅផ្នែកនគរបាលជាតិ នៃក្រសួងមហាផ្ទៃ អង្គភាពម្ចាស់ការហិរញ្ញវត្ថុ និងស្វ័យាភិបាលសេដ្ឋកិច្ច ការរក្សាក្របខ័ណ្ឌនៅក្រសួង ស្ថាប័នដើម នូវមន្ត្រីដែលបំរើការងារ ការទូតនៅបរទេស ចំពោះមន្ត្រី បុគ្គលិក រាជការ ស៊ីវិលដែលមានចែងក្នុងមាត្រា ១-២-៣-៤ ៥-៦ គឺអនុវត្តអោយបានត្រឹមត្រូវ តាមច្បាប់ដែលមានជាធរមាន និង ស្របទៅតាមនិតិវិធី ។

មាត្រា ៨ ការដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់ក្រសួង_ស្ថាប័ន និង មន្ត្រី បុគ្គលិក រាជការ ស៊ីវិល ដែលមានឈ្មោះចែងក្នុងឧបសម្ព័ន្ធទី ១ ទី២ ទី៣ ទី៤ ទី៥ ទី៦ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# II- ការងារបណ្តាក្រសួង

## ១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៩៧

**ប្រកាសលេខ ៣៥០ ប្រក.សហវ.ពដ**

**ស្តីពី**

**ការបំពេញបន្ថែមប្រកាសលេខ ៣១៩ ប្រក.សហវ.ពដ**

**ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីនីតិវិធីអនុវត្តសិទ្ធិធ្វើអាជ្ញាប័ណ្ណ**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា